ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៧

# ដំណឹងជ្រើសរើសបុគ្គលិកបន្ទាន់

ខុមហ្វ្រែល គឺជាគណៈកម្មាធិការឯករាជ្យ អព្យាក្រឹត្យ មិនរកកំរៃ និងមិនទទួលឥទ្ធិពលពីគណបក្សនយោបាយ និងរាជរដ្ឋាភិបាល។ បេសកកម្មរបស់ខុមហ្វ្រែល គឺជួយបង្កើតបរិយាកាស គួរជាទីពេញចិត្ត និងមានព័ត៌មានគ្រប់គ្រាន់ ដោយទី១ដើម្បី / ឱ្យមានដំណើរការបោះឆ្នោតដោយសេរី និងយុត្តិធម៌ តាមរយៈការបញ្ចុះបញ្ចូល តស៊ូមតិ និងទី២ /ដើម្បីឱ្យមានអត្ថន័យ នៃដំណាក់កាលក្រោយពេលបោះឆ្នោត តាមរយៈការអប់រំ និងវេទិកាសាធារណៈ ក្នុងគោលបំណងជំរុញលើកទឹកចិត្តប្រជាពលរដ្ឋឱ្យចូលរួម ក្នុងកិច្ចការនយោបាយ និងការធ្វើសេចក្តីសំរេចនានា។

ខុមហ្វ្រែលត្រូវការជ្រើសរើសបុគ្គលិកពេញម៉ោងតួនាទីជា **ជំនួយការ** នៃផ្នែកអង្កេតចំនួនមួយ (០១)រូប ប្រចាំការស្នាក់ការកណ្តាល នៅរាជធានីភ្នំពេញ។

## តួនាទី និងការទទួលខុសត្រូវ៖

- ប្រមូល និងតាមដានព័ត៌មានដែលចុះផ្សាយលើប្រព័ន្ធផ្សព្វផ្សាយ បណ្តាញសង្គម គេហទំព័រ ផ្សេងៗ
- បញ្ចូលទិន្នន័យរាល់ព័ត៌មានដែលទទួលបាន
- ទំនាក់ទំនង និងតាមដានសកម្មភាពការងារជាមួយមន្ត្រីភាគីពាក់ព័ន្ធផ្សេងៗ
- ចងក្រងព័ត៌មាន និងសហការ ធ្វើរបាយការណ៍នៃកម្មវិធីផ្នែកអង្កេត
- ជួយនូវរាល់ការងារផ្សេងៗ ដែលមានការស្នើសុំពីអ្នកគ្រប់គ្រងផ្ទាល់ ឬផ្នែកអង្កេត
- ទទួលខុសត្រូវចំពោះអ្នកសម្របសម្រួលផ្នែកអង្កេត

## លក្ខខ័ណ្ឌតម្រូវ ៖

- និស្សិតទើបបញ្ចប់ការសិក្សា ឬកំពុងសិក្សាឆ្នាំទី៣ នៃមហាវិទ្យាល័យវិទ្យាសាស្ត្រសង្គម មុខជំនាញច្បាប់ វិទ្យាសាស្ត្រនយោបាយ រដ្ឋបាលសាធារណៈ ទំនាក់ទំនងអន្តរជាតិ សង្គមវិទ្យា ឬមុខជំនាញសេដ្ឋកិច្ច
- មានបទពិសោធន៍ការងារទាក់ទងនឹងផ្នែកខាងលើកាន់តែប្រសើរ
- មានទំនាក់ទំនង និងចេះប្រាស្រ័យទាក់ទងល្អ
- មានចំណេះដឹងផ្នែកកុំព្យូទ័រការិយាល័យ និងប្រព័ន្ធផ្សព្វផ្សាយសង្គម
- មានសមត្ថភាពប្រើប្រាស់ភាសាអង់គ្លេសបានល្អ ឬកម្រិតមធ្យម
- មានឆន្ទៈមោះមុត ទំនួលខុសត្រូវខ្ពស់ និងស្មារតីជាក្រុម និងគំនិតច្នៃប្រឌិតក្នុងការបំពេញការងារ
- ស្មោះត្រង់ តស៊ូក្នុងការបំពេញការងារ

បេក្ខជន/បេក្ខនារី ដែលមានចំណាប់អារម្មណ៍អាចផ្ញើប្រវត្តិរូបសង្ខេប (CV and Cover Letter) មកកាន់ស្នាក់ការអង្គការខុមហ្វ្រែល ផ្ទះលេខ១៣៨ ផ្លូវលេខ១២២ សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ឬតាមរយៈអ៊ីម៉ែល៖ seanbunrith@comfrel.org។ កាលបរិច្ឆេទនៃការឈប់ទទួលពាក្យ៖ ថ្ងៃទី**០៥ ខែឧសភា** ឆ្នាំ២០១៧ វេលាម៉ោង ០៥ ល្ងាច។

**សំគាល់៖

- បេក្ខជនជាស្ត្រី និងអ្នកដែលមានបទពិសោធន៍ដូចតួនាទីខាងលើត្រូវបានលើកទឹកចិត្តក្នុងការដាក់ពាក្យ
- មានតែបេក្ខជន/បេក្ខនារីជាប់ជុំដំបូងត្រូវបានណាត់ធ្វើការសម្ភាសន៍ក្នុងរយៈពេល០១សប្តាហ៍ក្រោយពេលឈប់ទទួលពាក្យ

Vision: A democratic society that democratization in particular democratic elections are promoted and qualified to bring benefits to people.



ទីស្នាក់ការកណ្តាល ៖ ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ ទឹកល្អក់ ១ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Central Office : #138, Street. 122, TeukLaak I, TuolKork, Phnom Penh, CAMBODIA.
P.O. Box1145, Phone : (855) 23 884 150 Fax: (855) 23 885 745 E-mail : comfrel@online.com.kh Website: www.comfrel.org